**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 13-Oct-21, 08:00
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើបន្ទាន់របស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំដាក់ឯកសារតែមួយភាសា និងសុំការពន្យារពេលនៃកាលបរិច្ឆេទដាក់ឯកសារ**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

Laure DESFORGES
Isabelle DURAND
Emmanuel ALTIT
Martine JACQUIN
Daniel LOSQ
Christine MARTINEAU

<u>នៅចំពោះមុខ</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ីម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE- MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

០០២/១៩-០៩-២០០៧-អវតក/អជតក

ឡោ ជុនធី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Lyma NGUYEN
Mahesh RAI
Nushin SARKARATI

ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Brenda J. HOLLIS

**ជនជាប់ចោទ៖**
ខៀវ សំផន

**សហមេធាវីការពារក្តី៖**
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

1. សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") ស្នើសុំការអនុញ្ញាតដាក់ឯកសារតែមួយភាសា និងស្នើសុំកាលបរិច្ឆេទឆាប់រហ័ស សម្រាប់ចម្លើយតប និងការឆ្លើយតបនានា ព្រមទាំងស្នើសុំឧបាស្រ័យបណ្តោះអាសន្នបន្ទាន់ មុននឹងមានសេចក្តីសម្រេចជាចុងក្រោយ។ បញ្ហានេះគឺបន្ទាន់ ដោយសារតែពាក់ព័ន្ធជាមួយសេចក្តីសម្រេចរបស់ការិយាល័យរដ្ឋបាល ដែលមួយផ្នែកនៃការសម្រេចនោះ នឹងចូលជាធរមាននៅដំណាច់ខែតុលា ដែលអាចនឹងមានអានុភាពមិនអាចកែប្រែបាន។

2. ការដាក់សារណា (សំណើរ) នឹងពិតជាដោះស្រាយការយល់ច្រឡំដោយការិយាល័យរដ្ឋបាល ពាក់ព័ន្ធនឹងក្របខណ្ឌសម្រាប់ការតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រោមវិធានផ្ទៃក្នុង ហើយដើម្បីស្វែករកដីកាបង្គាប់សម្រាប់ការិយាល័យរដ្ឋបាល ដើម្បីធានាដល់ការបន្តការងារបណ្តោះអាសន្នដល់បុគ្គលិកគ្រប់គ្រាន់ជូនសហមេធាវីនាំមុខ ក្នុងការតំណាងផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព។

3. កាលពីចុងខែកញ្ញា សហមេធាវីនាំមុខអន្តរជាតិ បានដាក់អនុស្សរណៈពីរ ជូនទៅការិយាល័យរដ្ឋបាល ដោយពន្យល់អំពីតម្រូវការលើធនធានរបស់គាត់ សម្រាប់ត្រីមាសខាងមុខ និងពេលវេលានៅសល់សម្រាប់សំណុំរឿង[1]។ ទំហំការងារយ៉ាងច្រើន ដែលនៅសល់ត្រូវបំពេញ (ទោះបីថាមិនទាំងអស់ក្តី) ហើយដែលការិយាល័យរដ្ឋបាល បានទទួលស្គាល់ថាស្ថិតនៅក្នុងអាណត្តិការងាររបស់យើង រួមទាំងការប្រជុំជាមួយដើមបណ្តឹងរដ្ឋប្បវេណី ការចាត់ចំណាត់ថ្នាក់ឡើងវិញលើសារណា និងសេចក្តីរាយការណ៍អំពីការអនុវត្តសំណង។ ដោយផ្អែកលើការទំនាក់ទំនងកន្លងមក ជាមួយការិយាល័យរដ្ឋបាល សហមេធាវីនាំមុខរំពឹងថា ធនធានសម្រាប់ការផ្តល់ប្រឹក្សារបស់សហមេធាវីនាំមុខ នឹងត្រូវបន្តក្នុងកម្រិតមួយ បើទោះបីជាពេលម៉ោងបំពេញការងារ របស់សហមេធាវីនាំមុខអន្តរជាតិ អាចត្រូវបានកាត់បន្ថយក្តី[2]។ ប៉ុន្តែនៅល្ងាចថ្ងៃសុក្រទី0១ ខែតុលា ឆ្នាំ២0២១ សហមេធាវី

---

[1] អនុស្សារណៈផ្ញើពីសហមេធាវីអន្តរជាតិជូនចំពោះការិយាល័យរដ្ឋបាល ឆ្លើយតបៈ ធនធានបុគ្គលិកសម្រាប់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខែតុលា ទៅខែធ្នូ ឆ្នាំ២0២១ កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២0២១ (ឯកសារភ្ជាប់ទី១)។ អនុស្សារណៈផ្ញើពីសហមេធាវីអន្តរជាតិនាំមុខជូនចំពោះការិយាល័យរដ្ឋបាល ឆ្លើយតបៈ ធនធានបុគ្គលិករបស់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខែតុលា ទៅខែធ្នូ ឆ្នាំ២0២១ កាលពីថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២0២១ (ឯកសារភ្ជាប់ទី២)។

[2] សារឆ្លើយឆ្លងទាំងអស់ នឹងដាក់ភ្ជាប់ជាមួយសារណានេះ នៅពេលដាក់ជូនអង្គជំនុំជម្រះ។ មានតែឯកសារគន្លឹះប៉ុណ្ណោះ ត្រូវបានដាក់ជូនជាមួយសារណានេះ ដើម្បីចំណេញពេល។

នាំមុខអន្តរជាតិ ទទួលបានព័ត៌មានពីការិយាល័យរដ្ឋបាលថា (១) ការងារមួយផ្នែកដែលបានរៀបរាប់ នឹងមិនត្រូវទទួលបានការទូទាត់ឡើយ ដោយសារតែការងារទាំងនោះ ត្រូវបានចាត់ទុកថាស្ថិតក្រៅអាណត្តិការងាររបស់សហមេធាវីនាំមុខ និង (២) ការផ្តល់ប្រឹក្សាសម្រាប់ខាងអន្តរជាតិនឹងត្រូវបញ្ចប់នៅដំណាច់ខែតុលា[3]។ ភ្លាមៗនោះ និងជាថ្មីម្តងទៀត នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ និងថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២១ សហមេធាវីនាំមុខអន្តរជាតិ បានស្នើសុំការបញ្ជាក់បំភ្លឺលើចំណុចទីពីរពាក់ព័ន្ធថា តើមានការផ្តល់ប្រឹក្សាថ្មីដែរឬអត់ បើទោះបីជានៅក្នុងលក្ខខណ្ឌផ្សេងក្តី សម្រាប់ខែវិច្ឆិកា និងខែធ្នូ[4]។ ដោយមិនបានទទួលការបញ្ជាក់បំភ្លឺ សហមេធាវីនាំមុខអន្តរជាតិ បានដាក់អនុស្សរណៈបន្ថែមទៀត នៅថ្ងៃទី០៥ ខែតុលា ដោយបានស្នើឱ្យការិយាល័យរដ្ឋបាលពិចារណាម្តងទៀត នូវសេចក្តីសម្រេចរបស់ខ្លួន[5]។ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ការិយាល័យរដ្ឋបាលបានឆ្លើយតបដោយបានផ្តល់អនុស្សរណៈមួយ ដែលបញ្ជាក់ពីហេតុផលរបស់ខ្លួន និងបដិសេធក្នុងការពិចារណាម្តងទៀត នូវសេចក្តីសម្រេចមុនរបស់ខ្លួន[6]។

## ២. ច្បាប់ជាធរមាន

4. មាត្រា៧.១ នៃសេចក្តីណែនាំអនុវត្ត តម្រូវថារាល់ឯកសារទាំងអស់ ត្រូវដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬភាសាបារាំង។ ប៉ុន្តែមាត្រា ៧.២ បានចែងថា “នៅក្នុងកាលៈទេសៈពិសេស សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក អាចអនុញ្ញាតឱ្យភាគីណាមួយ ដាក់ឯកសារជាភាសាបារាំង ឬភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែបន្ទាប់មក ភាគីត្រូវដាក់ឯកសារជាភាសាខ្មែរ ដែលបានបកប្រែរួច ឱ្យបានឆាប់រហ័សបំផុត”។

5. អង្គជំនុំជម្រះតុលាការកំពូល ក៏បានពន្យល់បកស្រាយបន្ថែមថា “ការអនុញ្ញាតឱ្យដាក់ឯកសារតែមួយភាសាជាភាសាអង់គ្លេស ឬភាសាបារាំង បន្ថែមលើការធ្វើយុត្តិកម្មអំពីកាលៈទេសៈពិសេស ចាំបាច់ត្រូវផ្អែកលើការសន្មតថា សមាសភាពជាតិនៅក្នុងអង្គភាពដាក់ឯកសារ ត្រូវបានជូនដំណឹង

---

[3] សូមមើល ការផ្ញើរអ៊ីម៉ែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខអន្តរជាតិ (ឯកសារភ្ជាប់ទី៣)។

[4] សូមមើល ការផ្ញើរអ៊ីម៉ែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខអន្តរជាតិ (ឯកសារភ្ជាប់ទី៣)។

[5] អនុស្សរណៈផ្ញើពីសហមេធាវីអន្តរជាតិជូនចំពោះការិយាល័យរដ្ឋបាល ឆ្លើយតប៖ ធនធានបុគ្គលិកសម្រាប់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខែតុលា ទៅខែធ្នូ ឆ្នាំ២០២១ កាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ (ឯកសារភ្ជាប់ទី៤)។

[6] អនុស្សរណៈផ្ញើពីការិយាល័យរដ្ឋបាល ជូនចំពោះសហមេធាវីអន្តរជាតិ ហេតុផលក្នុងសេចក្តីសម្រេចលើសំណើធនធាន របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ ខែតុលា ទៅខែធ្នូ ឆ្នាំ២០២១ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ (ឯកសារភ្ជាប់ទី៥)។

គ្រប់គ្រាន់អំពីខ្លឹមសារនៃឯកសារ និងពុំបានទទួលរងនូវការប៉ះពាល់ដល់សិទ្ធិ នៅក្នុងការបង្ហាញពីជំហររបស់ខ្លួនឡើយ”[7]។

6. សេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក បានបញ្ជាក់ថា ចម្លើយតបនិងការឆ្លើយតប ត្រូវដាក់បន្តបន្ទាប់គ្នា នៅក្នុងរយៈពេលដប់ថ្ងៃ និងប្រាំថ្ងៃនៃប្រតិទិន ក្រោយពេលទទួលបានការជូនដំណឹង[8]។

## ៣. សារណា

7. កាលៈទេសៈបច្ចុប្បន្នជាកាលៈទេសៈពិសេស ដោយសារតែភាពបន្ទាន់។

8. ជាការចាំបាច់ត្រូវមានសេចក្តីសម្រេច យ៉ាងហោចណាស់លើឧបាស្រ័យបណ្តោះអាសន្ន នៅមុនដំណាច់ខែតុលា នៅពេលដែលសេចក្តីសម្រេចរបស់ការិយាល័យរដ្ឋបាល លើការបញ្ចប់ធនធានប្រឹក្សារបស់សហមេធាវីនាំមុខអន្តរជាតិ ចូលជាធរមាន។

9. ការដាក់សារណានេះត្រូវបានរៀបចំឡើងយ៉ាងឆាប់រហ័សបំផុត។ ដោយសារតែពិធីបុណ្យភ្ជុំបិណ្ឌ សារណានេះមិនអាចដាក់នៅមុនថ្ងៃនេះបានទេ។

10. សហមេធាវីនាំមុខប៉ាន់ប្រមាណថា ការដាក់សារណារបស់ខ្លួន ដែលលើកឡើងអំពីកំហុសឆ្គង នៅក្នុងសេចក្តីសម្រេចរបស់ការិយាល័យរដ្ឋបាល នឹងត្រូវរៀបចំរួចរាល់ជាភាសាតែមួយ ជាមួយនឹងបញ្ជីឯកសារយោងពេញលេញ នៅត្រឹមថ្ងៃទី១៨ ខែតុលា។ ប៉ុន្តែដោយសារតែសារណាអាចនឹងលើសពីម្ភៃទំព័រ ទើបការបកប្រែជាភាសាខ្មែរ អាចនឹងចំណាយពេលយ៉ាងហោចណាស់មួយសប្តាហ៍។ មានការប៉ាន់ប្រមាណថា ការដាក់សារណាជាពីរភាសា មិនអាចធ្វើឡើងនៅមុនថ្ងៃទី២៦ ខែតុលា ឡើយ។ កាលបរិច្ឆេទសម្រាប់ការដាក់ចម្លើយតប គឺនៅថ្ងៃទី៥ ខែវិច្ឆិកា ឬក្រោយនោះ ដោយផ្អែកលើកាលបរិច្ឆេទនៃការជូនដំណឹង។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល មិនអាចធ្វើការសម្រេច នៅមុនពេលសេចក្តីសម្រេច ដែលរងការជំទាស់របស់ការិយាល័យរដ្ឋបាល ត្រូវបានអនុវត្តឡើយ។

---

[7] ឯកសារ E463/1/1/1 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់សារណាតបតែមួយភាសា ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៨។

[8] មាត្រា ៨.៣ និង ៨.៤ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ នៅចំពោះមុខ អ.វ.ត.ក។

11. ប្រសិនបើធនធានសម្រាប់ការប្រឹក្សា ត្រូវបានបញ្ចប់នៅដំណាច់ខែនេះ គឺពិតជាមិនអាចត្រឡប់មករកស្ថានភាពបច្ចុប្បន្ននេះឡើយ ដោយសារតែទីប្រឹក្សារបស់យើងដែលយល់ដឹងច្បាស់លើសំណុំរឿង និងការងារដែលចាំបាច់សម្រាប់ដំណាក់កាលនេះ នឹងប្រហែលជាចាកចេញពីប្រទេសកម្ពុជា និង/ឬ ស្វែងរកការងារផ្សេង។

12. ដោយផ្អែកលើស្ថានភាពនេះ នៅថ្ងៃទី០៨ ខែតុលា សហមេធាវីនាំមុខបានស្នើដល់ការិយាល័យរដ្ឋបាលឱ្យ ពន្យារសេចក្តីសម្រេចរបស់ពួកគេ (ដោយបន្តធនធានប្រឹក្សាដែលមានស្រាប់) រហូតដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូល អាចចេញសេចក្តីសម្រេច[9]។ សហមេធាវីនាំមុខ មិនបានទទួលនូវចម្លើយតប។

13. ហេតុដូច្នេះ សហមេធាវីនាំមុខ ស្នើសុំការអនុញ្ញាតដាក់សារណាជាភាសាតែមួយ ហើយស្នើដល់អង្គជំនុំជម្រះ ឱ្យកំណត់កាលបរិច្ឆេទឆាប់រហ័ស សម្រាប់ចម្លើយតប និងការឆ្លើយតបនានា។ សហមេធាវីនាំមុខរំពឹងថា ការិយាល័យរដ្ឋបាលនឹងមានភាពងាយស្រួលផងដែរ ប្រសិនបើពួកគេបានដឹងអំពីកាលបរិច្ឆេទនេះជាមុន។ សហមេធាវីនាំមុខសូមធានាដល់អង្គជំនុំជម្រះថា សហមេធាវីនាំមុខជាតិ បានទទួលព័ត៌មានពេញលេញអំពីបញ្ហាទាំងអស់នេះ ហើយនៅក្នុងករណីនេះ មិនមានផលប៉ះពាល់អ្វីទាំងអស់ តាមរយៈការដាក់ឯកសារតែមួយភាសានេះ។

14. ជម្រើសផ្សេងទៀត សហមេធាវីនាំមុខស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីបង្គាប់បណ្តោះអាសន្នដើម្បីបន្តការងារដល់បុគ្គលិករបស់សហមេធាវីនាំមុខ ដោយព្យួរទុកសេចក្តីសម្រេចលើបញ្ហាកាត់បុគ្គលិកនេះសិន។ ម៉ោងបំពេញការងាររបស់សហមេធាវីអន្តរជាតិនាំមុខអាចកាត់បន្ថយបានក្នុងអំឡុងពេលនេះ ដើម្បីធានាថាការចំណាយមិនត្រូវបានកើនឡើងសម្រាប់តុលាការ។

សហមេធាវីនាំមុខសូមស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះតុលាការកំពូល៖

(១) **អនុញ្ញាត**ឱ្យសហមេធាវីនាំមុខ ដាក់សារណាលើបញ្ហានេះ ជាភាសាអង់គ្លេស នៅត្រឹមថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០២១ ដោយឯកសារបកប្រែជាភាសាខ្មែរ នឹងដាក់ជូនឲ្យបានឆាប់រហ័សបំផុត

(២) **បង្គាប់**ថា ចម្លើយតបចំពោះសារណា ត្រូវដាក់ជាមួយភាសា នៅត្រឹមថ្ងៃទី២២ ខែតុលា ឆ្នាំ ២០២១ ដោយភាសាទីពីរត្រូវដាក់ឱ្យបានឆាប់រហ័សបំផុតតាមក្រោយ

---

[9] សូមមើល ការផ្ញើរអ៊ីម៉ែលរវាងការិយាល័យរដ្ឋបាល និងសហមេធាវីនាំមុខអន្តរជាតិ (ឯកសារភ្ជាប់ទី៣)។

(៣) **បង្គាប់**ថា ការឆ្លើយតបត្រូវដាក់ជាមួយភាសា នៅត្រឹមថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ ដោយភាសាទីពីរ ត្រូវដាក់ឱ្យបានឆាប់រហ័សបំផុតតាមក្រោយ។

ឬ ជម្រើសផ្សេងទៀត៖

(៤) **បង្គាប់**ថា ធនធានជាទីប្រឹក្សាបច្ចុប្បន្នរបស់សហមេធាវីនាំមុខ ត្រូវបានរក្សាដដែល ដោយព្យួរទុកសេចក្តីសម្រេចចុងក្រោយលើបញ្ហានេះ ដោយអង្គជំនុំជម្រះតុលាការកំពូល។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | Megan HIRST<br>សហមេធាវីនាំមុខអន្តរជាតិ | ទីក្រុងឡុងដ៍ | |